# កិច្ចតែងការបង្រៀន

មុខវិជ្ជា : ផែនដី និងបរិស្ថានវិទ្យា
ថ្នាក់ទី : ១១
ជំពូកទី១ : ភពផែនដី
មេរៀនទី៦ : ភ្នំភ្លើង
រយៈពេលបង្រៀន: ៥០ នាទី
បង្រៀនដោយ៖ អ្នកគ្រូ រឹម ៉ានី

## I. វត្ថុបំណង

- ➢ បន្ទាប់ពីសិក្សាមេរៀននេះចប់ សិស្សនឹង៖
- **វិជ្ជាសម្បទា:** រៀបរាប់ពីមូលហេតុ និងទីតាំងនៃភ្នំភ្លើង និងរូបធាតុដែលផ្ទុះចេញពីភ្នំភ្លើង(បន្ទុះខ្លាំង និងបន្ទុះស្ងប់)បានត្រឹមត្រូវតាមរយៈការពិសោធន៍ និងវីដេអូជំនួយ។
- **បំណិនសម្បទា:** បង្កើតបន្ទុះភ្នំភ្លើងខ្លាំង និងបន្ទុះស្ងប់តាមរយៈគម្រូភ្នំភ្លើងសិប្បនិម្មិត។
- **ចរិយាសម្បទា:** ចេះសង្កេត តាមដានពីបន្ទុះភ្នំភ្លើងដែលកើតមានឡើងថ្មីៗនៅលើពិភពលោក និងចូលរួមសិក្សាស្រាវជ្រាវបន្ថែមពីមូលហេតុដែលបណ្តាលឱ្យប្រទេសមួយចំនួនកើតមានបន្ទុះភ្នំភ្លើងបានជាប្រចាំ។

## II. ខ្លឹមសារមេរៀន

១. ភ្នំភ្លើង និងផ្លាកតិចតូនិច
២. បន្ទុះភ្នំភ្លើង
 ២.១. បន្ទុះស្ងប់
 ២.២. បន្ទុះខ្លាំង

## III. សម្ភារៈបង្រៀន

- សៀវភៅផែនដីវិទ្យាថ្នាក់ទី១១សម្រាប់សិស្ស ទំព័រទី ៥០-៥៦ របស់ក្រសួងអប់រំ យុវជន និងកីឡា។
- សៀវភៅគ្រូមុខវិជ្ជាផែនដីវិទ្យា ថ្នាក់ទី១១ ទំព័រទី ៤៨-៥៦
- រូបភាព វីដេអូជំនួយ
- សន្លឹកកិច្ចការសិស្ស
- ១.ឈើគូស អាម៉ូញ៉ូមឌីក្រូម៉ាត(NH4)2CrO7 , ចានដែកធំ១
 ២.ភ្នំសប្បនិមិត្ត កែវបេសឺ ម្សៅមេនំប៉័ង1កញ្ចប់ សាប៊ូលាងចាន1ដបតូច លាក់ពណ៌1កញ្ចប់ ទឹកខ្មេះមួយដប ថាសជ័រ ជីឡៅ ស្លាបព្រា ចង្កឹះ ស្រោមដៃ កន្ត្រៃ ដបជ័រ1 ។

## IV. លំនាំនៃការបង្រៀន៖ វិធីសាស្ត្របង្រៀនបែបរិះរកដោយបញ្ហាបស្នែម តាមគម្រូ 5D

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១ លំនឹងថ្នាក់** (២នាទី) | | |
| – ត្រួតពិនិត្យវិន័យ សណ្តាប់ធ្នាប់ អនាម័យ<br>– ត្រួតពិនិត្យអវត្តមានសិស្ស | – រដ្ឋបាលថ្នាក់ | – សិស្សអង្គុយតាមកន្លែងស្ងៀមស្ងាត់<br>– ប្រធានថ្នាក់រាយការណ៍ |
| **ជំហានទី២ រំលឹកមេរៀនចាស់**( ៥ នាទី ) | | |

| | | |
|---|---|---|
| – សួរសំណួររំលឹកមេរៀនចាស់ដោយការឆ្លើយស្ម័គ្រចិត្ត<br>– នៅតាមព្រំដែនផ្លាកតិចតូនិចមានបាតុភូតធម្មជាតិអ្វីខ្លះ?<br>– តើរញ្ជួយដីច្រើនកើតឡើងនៅកន្លែងណា ?<br><br>– គ្រូបង្ហាញរូបភាពជំនួយ តើរូបភាពនេះបង្ហាញពីអ្វី ?<br><br>– គ្រូបង្ហាញវីដេអូជំនួយពីភ្នំភ្លើង។ (Video)<br>– តើភ្នំភ្លើងច្រើនកើតនៅកន្លែងណាខ្លះ (គ្រូបង្ហាញរូបភាព)? | – រំលឹកសិស្សអំពីចំណេះដឹងដែលបានរៀនកាលពីពេលមុន<br><br>– សំណួរបំផុសចូលមេរៀនថ្មី<br><br>• វីដេអូបាតុភូតភ្នំភ្លើងមួយចំនួននៅលើផែនដី<br> | – សិស្សឆ្លើយ<br><br>– មានរញ្ជួយដី បន្ទុះភ្នំភ្លើង និងបំណាក់ស្រុត ជ្រោះ ទន្លេ ស្ទឹង បឹង......។<br>– រញ្ជួយដីច្រើនកើតឡើងនៅតាមគែមនៃផ្លាក ឬតាមព្រំដែនផ្លាកតិចតូនិច។<br><br>– រូបភាពនេះបង្ហាញពីភ្នំភ្លើងផ្ទុះ<br><br>• សិស្សសង្កេតបាតុភូតភ្នំភ្លើង និងកត់ត្រា<br><br>•ភ្នំភ្លើងភាគច្រើនកើតនៅតាមព្រំដែនផ្លាកតិចតូនិចក្បែរមហាសមុទ្រប៉ាស៊ីហ្វិក ។ និងផ្ទុះនៅតាមព្រំដែនបែកចេញ ជំនួបគ្នា ជ្រួស និងចំណុចក្តៅ (កណ្តាលផ្លាក)។ |
| **ជំហានទី៣ មេរៀនថ្មី ( ៣៥ នាទី )** | | |
| •សរសេរចំណងជើងមេរៀន<br>ចូលរួម(Engage)<br>–គ្រូសួរសំណួរផ្តើមចេញពីមេរៀន<br>–ភ្នំភ្លើងគឺជាអ្វី?<br>–តើបន្ទុះខ្លាំង និងបន្ទុះស្ងប់កើតឡើងយ៉ាងដូចម្តេច ? ហើយបង្កើតឱ្យមានអ្វីខ្លះ ?<br><br>➢ តើរូបទាំងពីរ បង្ហាញពីបន្ទុះភ្នំភ្លើងដូចម្តេចខ្លះ ?<br>–ឱ្យសិស្សកំណត់និយមន័យដោយផ្អែកលើរូបភាពភ្នំភ្លើង និងវីដេអូជំនួយ។ | រូបភាព<br><br> | • ភ្នំភ្លើង ជាភ្នំដែលកើតឡើងនៅពេលសិលារលាយ ហៅថាម៉ាក់ម៉ាហូរចេញមកលើផ្ទៃផែនដី ។<br><br>– រូបនេះបង្ហាញពីបន្ទុះភ្នំភ្លើងខ្លាំង និងបន្ទុះស្ងប់ ។ |

## សំណួរគន្លឹះ

**តើបន្ទុះភ្នំភ្លើងខ្លាំង និងបន្ទុះស្ងប់មានលក្ខណៈយ៉ាងដូចម្ដេច?**

| | | |
|---|---|---|
| **រុករក(Explore)**<br>• ចែកសិស្សជា ៤ ក្រុម ហើយប្រគល់សម្ភារៈពិសោធន៍ ។<br>• ណែនាំពីសម្ភារៈពិសោធន៍ ។<br>• បញ្ជាក់៖ សិស្សអាចស្វែងរកព័ត៌មានតាមប្រភពអ៊ីនធឺណែត ពីសៀវភៅ ឬឯកសារផ្សេងៗទៀត។ | រូបភាព<br> | • សិស្សចូលតាមក្រុមនីមួយៗ បន្ទាប់មកគ្រូណែនាំពីរបៀបប្រើប្រាស់សម្ភារៈពិសោធន៍នីមួយៗ<br>• សិស្សស្ដាប់គ្រូពន្យល់ពីរបៀបប្រើប្រាស់ |
| ❖ ចូរឆ្លើយសំណួរដើម្បីបង្កើតសមត្ថកម្មទាក់ទងនឹងសំណួរគន្លឹះពី បន្ទុះស្ងប់ និងបន្ទុះខ្លាំងទៅតាមក្រុមឬសមាជិកនីមួយៗ ។ | • បន្ទុះខ្លាំង គឺជាពំនូកនៃកម្ទេច និងឧស្ម័នបានព្រួសចេញពី ភ្នំភ្លើងយ៉ាងលឿន បន្ទុះនេះបានធ្វើឲ្យសិលារលាយបាចសាច ជាបំណែកតូចៗកករឹង ក្នុងបរិយាកាស ។<br>• បន្ទុះភ្នំភ្លើងស្ងប់ គឺជាទន្លេកំអែភ្នំភ្លើងក្ដៅពណ៌ក្រហមដែលហូរចេញពីបន្ទុះភ្នំភ្លើង ហៅថាលំហូរកំអែភ្នំភ្លើង ។ ហើយវាហូរចេញមកក្រៅយ៉ាងស្ងៀម ។ | • បន្ទុះខ្លាំង គឺជាពំនូកនៃកម្ទេច និងឧស្ម័នបានព្រួសចេញពី ភ្នំភ្លើងយ៉ាងលឿន បន្ទុះនេះបានធ្វើឲ្យសិលារលាយបាចសាច ជាបំណែកតូចៗកករឹង ក្នុងបរិយាកាស ។<br>• បន្ទុះភ្នំភ្លើងស្ងប់ គឺជាទន្លេកំអែភ្នំភ្លើងក្ដៅពណ៌ក្រហមដែលហូរចេញពីបន្ទុះភ្នំភ្លើង ហៅថាលំហូរកំអែភ្នំភ្លើង ។ ហើយវាហូរចេញមកក្រៅយ៉ាងស្ងៀម ។ |
| •គ្រូចែកសន្លឹកកិច្ចការ និងណែនាំខ្លះៗអំពីរបៀបប្រើប្រាស់ និងកត់ត្រា ។<br><br>•សិស្សចាប់ផ្ដើមពិភាក្សាគ្នាពីរបៀបបង្កើតគំរូភ្នំភ្លើង ជាប្រភេទបន្ទុះស្ងប់ ។<br>• គ្រូសម្របសម្រួលពីការបង្កើតគំរូភ្នំភ្លើង<br><br>•សិស្សចាប់ផ្ដើមពិភាក្សាគ្នាពីរបៀបបង្កើតគំរូភ្នំភ្លើង ជាប្រភេទបន្ទុះខ្លាំង ។<br>• គ្រូសម្របសម្រួលពីការបង្កើតគំរូភ្នំភ្លើង<br><br>•ចូលសង្កេតពីសារធាតុដែលចេញពីដប និងលក្ខណៈនៃការផ្ទុះរបស់ភ្នំភ្លើង មានលក្ខណៈដូចម្ដេច ? | • រៀបចំសម្ភារៈពិសោធន៍<br>➢ ពិសោធន៍ទី១៖<br>ចាប់ផ្ដើមដោយយកអាម៉ូញ៉ូមឌីក្រូម៉ាតពូនជាភ្នំ រួចដុតទៀន និងដុតអាម៉ូញ៉ូមឌីក្រូម៉ាតអោយឆេះក្នុងខ្យល់ ដែលមានអុកស៊ីសែនស្រាប់<br>➢ ពិសោធន៍ទី២៖<br>ចាប់ផ្ដើមដោយការបង្កើតភ្នំសប្បនិមិត្តពីស៊ីម៉ង់ទុកអោយស្ងួត ហើយកំពូលភ្នំលៃចោះយ៉ាងណាអោយល្មមអាចដាក់ដបទឹកសុទ្ធចូលបាន រួច៖ ដំណើរការពិសោធន៍ ទី២ ចាក់ម្សៅBaking Soda ៥ ស្លាបព្រាជ័រ ចូលក្នុងកែវ ទី១ ចាក់ល័ក្ខពណ៌ក្រហម១កញ្ចប់ចូលកែវទី២ ចាក់សាប៊ូលាងចានចំណុះ ១០០ ml ចូលកែវទី៣ ហើយចាក់ទឹកខ្មេះចូលកែវទី៤។ | • សិស្សទទួលយកក្រដាសសន្លឹកកិច្ចការ និងស្ដាប់ការណែនាំ<br><br>•សិស្សចាប់ផ្ដើមពិភាក្សាគ្នាពីរបៀបបង្កើតគំរូភ្នំភ្លើង<br><br>•សិស្សចាប់ផ្ដើមពិសោធន៍តាមក្រុមនីមួយៗ និងធ្វើការសង្កេតដោយយកចិត្តទុកដាក់តាមក្រុមនីមួយៗ ។ |

| | | |
|---|---|---|
| | ហើយចាក់លាយល្បាយក្នុងទី១ ទី២ ទី៣ ចូលក្នុងកែវតែមួយ រួចយកចង្កឹះកូរចូលគ្នាឱ្យសប់ ល្បាយទាំង៣។<br>បន្ទាប់មកចាក់ល្បាយនោះចូលក្នុងដបទឹកសុទ្ធ ដាក់បញ្ចូលក្នុងកំពូលភ្នំភ្លើង ចុងក្រោយ យើងចាក់ទឹកខ្មេះចំនួន ១០០ ml ចូលក្នុងដបល្បាយលាយរួច នោះបន្ទាប់មកយើងឃើញមានបន្ទុះនៃល្បាយពណ៌ក្រហមហៀរចេញមកក្រៅ។ | |
| •គ្រូឲ្យសិស្សពិសោធន៍គំរូភ្នំភ្លើង១៥នាទី (សិស្សរៀបចំសម្ភារៈពិសោធន៍ ដំណើរការការពិសោធន៍)៖ | •គ្រូឲ្យសិស្សពិសោធន៍គំរូភ្នំភ្លើង១៥នាទី និងឡើងរាយការណ៍៖ | |
| **ពន្យល់ (Explain)**<br>– ហៅតំណាងក្រុមនីមួយៗឡើងបកស្រាយលទ្ធផលបានពិភាក្សា។<br>– គ្រូសម្របសម្រួលសម្លើយសិស្ស។ | -គ្រូសម្របសម្រួលសម្លើយសិស្ស | • សិស្សឡើងរាយការណ៍ពីលទ្ធផល<br>• សិស្សឡើងបញ្ចេញមតិ<br>• សិស្សស្ដាប់គ្រូពន្យល់ |
| **ពង្រីកគំនិត(Elaborate/ Extend)**<br>-បន្ទាប់មកគ្រូចាប់ផ្ដើមសួរពង្រីកចំណេះដឹងសិស្ស៖ | -គ្រូចាប់ផ្ដើមសួរពង្រីកចំណេះដឹងសិស្ស | -សិស្សឆ្លើយតាមគំនិតយល់ឃើញ |
| -តាមពិសោធន៍ទី១៖ ហេតុអ្វីបានជាយើងចាក់សារធាតុទាំងនេះធ្វើឱ្យមានបន្ទុះបែបនេះឡើង?ហើយគេឱ្យឈ្មោះថាបន្ទុះអ្វី? | • ដោយសារមានល្បាយនៃសារធាតុគីមីមានប្រតិកម្មនឹងគ្នាទើបវាបញ្ចេញនូវល្បាពពុះពណ៌ក្រហម ហើយរាវហូរយ៉ាងលឿន។ គេឱ្យឈ្មោះថាបន្ទុះស្ងប់។<br>ធៀបនឹងគំរូពិតគឺដោយសារទឹកច្រើន និងស៊ីលីកាតិចបង្កើតមានកំអែ៤ ខាប់ ក្រមួន គ្រើម និងខ្ទើយ ដោយសារ ល្បាយ ស៊ីលីកាតិច និងទឹកច្រើន។ | • ដោយសារមានល្បាយនៃសារធាតុគីមីមានប្រតិកម្មនឹងគ្នាទើបវាបញ្ចេញនូវល្បាពពុះពណ៌ក្រហម ហើយរាវហូរយ៉ាងលឿន។ គេឱ្យឈ្មោះថាបន្ទុះស្ងប់។<br>ធៀបនឹងគំរូពិតគឺដោយសារទឹកច្រើន និងស៊ីលីកាតិចបង្កើតមានកំអែ៤ ខាប់ ក្រមួន គ្រើម និងខ្ទើយ ដោយសារ ល្បាយ ស៊ីលីកាតិច និងទឹកច្រើន ។ |
| -តាមពិសោធន៍ទី២៖ ហេតុអ្វីបានជាពេលគេដុតធាតុគីមី អាម៉ូញ៉ូមឌីក្រូម៉ាតបណ្ដាលអោយមានចំហេះបែកផ្កាភ្លើង និងព្រួសកាកសំណល់ពណ៌ខ្មៅចេញមក? | • ព្រោះអាម៉ូញ៉ូមឌីក្រូម៉ាតជាធាតុគីមីងាយឆេះក្នុងខ្យល់ពេលមានប្រតិកម្មគីមីជាមួយអុកស៊ីសែន និងបញ្ចេញឧស្ម័នមួយចំនួនបង្កើតជាសំពាធធ្វើអោយមានការផ្ទុះដូចលំនាំនៃបន្ទុះខ្លាំងដែរ | • ព្រោះអាម៉ូញ៉ូមឌីក្រូម៉ាតជាធាតុគីមីងាយឆេះក្នុងខ្យល់ពេលមានប្រតិកម្មគីមីជាមួយអុកស៊ីសែន និងបញ្ចេញឧស្ម័នមួយចំនួនបង្កើតជាសំពាធធ្វើអោយមានការផ្ទុះដូចលំនាំនៃបន្ទុះខ្លាំងដែរ |

| | | |
|---|---|---|
| – តើគេអាចព្យាករណ៍ ឬតាមដានដឹងមុនពីបន្ទុះភ្នំភ្លើងបានដែរឬទេ? តើអ្វីជាសញ្ញានៃបន្ទុះភ្នំភ្លើង? | •គេមិនអាចព្យាករណ៍ដឹងមុនបានយូរពីបន្ទុះភ្នំភ្លើងកើតទេ។ ប៉ុន្តែគេអាចស្មានពីស្ថានការណ៍មុនពេលវាផ្ទុះបានបន្តិចបន្តួចដែរតាមរយៈ ការមើលទៅលើសណ្ឋានដី មានសញ្ញាផ្សេង មានក្លិនឈ្ងៀមស្អាន់ធម៌ តាមដានពីផ្កាយរណប...។ | •គេមិនអាចព្យាករណ៍ដឹងមុនបានយូរពីបន្ទុះភ្នំភ្លើងកើតទេ។ ប៉ុន្តែគេអាចស្មានពីស្ថានការណ៍មុនពេលវាផ្ទុះបានបន្តិចបន្តួចដែរតាមរយៈ ការមើលទៅលើសណ្ឋានដី មានសញ្ញាផ្សេង មានក្លិនឈ្ងៀមស្អាន់ធម៌ តាមដានពីផ្កាយរណប...។ |
| **ជំហានទី៤ ពង្រឹងពុទ្ធិ(៦នាទី)** | | |
| **វាយតម្លៃ(Evaluate)**<br>–តើភ្នំភ្លើងមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ ?<br><br>– ហេតុដូចម្តេចបានជាគេត្រូវស្វែងយល់ និងតាមដានពីទីតាំង និងសណ្ឋានដីភ្នំភ្លើង? | –រំលឹកចំណុចសំខាន់ៗដែលបានរៀន<br>- គុណសម្បត្តិរួមមាន បង្កើតសណ្ឋានដីភ្នំខ្ពង់រាប កម្រងកោះជាច្រើន ដីសម្បូរជីជាតិដល់ការដាំដុះ និងមានប្រភេទរ៉ែជាច្រើនសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ...។<br>គុណវិបត្តរួមមាន ភ្លើងឆេះព្រៃប៉ះពាល់ដល់បរិស្ថានឬធាតុអាកាស និងអាកាសធាតុ ប៉ះពាល់ដល់អាយុជីវិត មនុស្ស សត្វ និងហេដ្ឋារចនាសម្ព័ន្ធ ។<br><br>-ដើម្បីព្យាករណ៍ពីកម្លាំងនៃបន្ទុះ ផ្តល់ព័ត៌មានដល់អ្នករស់នៅតំបន់ជិតភ្នំភ្លើងពីផលប៉ះពាល់ និងបង្ការខ្លួនពីគ្រោះថ្នាក់នៃភ្នំភ្លើងផ្សេងៗ ត្រៀមអាហារហូបចុកគ្រប់គ្រាន់ជាដើម។ | - គុណសម្បត្តិរួមមាន បង្កើតសណ្ឋានដីភ្នំខ្ពង់រាប កម្រងកោះជាច្រើន ដីសម្បូរជីជាតិដល់ការដាំដុះ និងមានប្រភេទរ៉ែជាច្រើនសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ...។<br>គុណវិបត្តរួមមាន ភ្លើងឆេះព្រៃប៉ះពាល់ដល់បរិស្ថានឬធាតុអាកាស និងអាកាសធាតុ ប៉ះពាល់ដល់អាយុជីវិត មនុស្ស សត្វ និងហេដ្ឋារចនាសម្ព័ន្ធ ។<br><br>-ដើម្បីព្យាករណ៍ពីកម្លាំងនៃបន្ទុះ ផ្តល់ព័ត៌មានដល់អ្នករស់នៅតំបន់ជិតភ្នំភ្លើងពីផលប៉ះពាល់ និងបង្ការខ្លួនពីគ្រោះថ្នាក់នៃភ្នំភ្លើងផ្សេងៗ ត្រៀមអាហារហូបចុកគ្រប់គ្រាន់ជាដើម។ |
| **ជំហានទី៥ បណ្តាំផ្ញើ ឬកិច្ចការផ្ទះ(២នាទី)** | | |
| • រហូតមកដល់បច្ចុប្បន្ន តើប្រទេសកម្ពុជាដែរឬទេ? ចូររកភស្តុតាងបញ្ជាក់? | – កិច្ចការស្រាវជ្រាវ | – កត់ត្រារួច យកទៅឆ្លើយនៅផ្ទះ |

# សន្លឹកកិច្ចការសិស្ស
# ប្រធានបទ គំរូបន្ទុះភ្នំភ្លើងស្ងប់ និងបន្ទុះខ្លាំង

**១.ទត្ថុបំណង**

- **វិជ្ជាសម្បទា:** រៀបរាប់ពីមូលហេតុ និងទីតាំងនៃភ្នំភ្លើង និងរូបធាតុដែលផ្ទុះចេញពីភ្នំភ្លើង(បន្ទុះខ្លាំង និងបន្ទុះស្ងប់)បានត្រឹមត្រូវតាមរយៈការពិសោធន៍ និងវីដេអូជំនួយ។
- **បំណិនសម្បទា:** បង្កើតបន្ទុះភ្នំភ្លើងខ្លាំង និងបន្ទុះស្ងប់តាមរយៈគម្រូភ្នំភ្លើងសិប្បនិម្មិត។
- **ចរិយាសម្បទា:** ចេះសង្កេត តាមដានពីបន្ទុះភ្នំភ្លើងដែលកើតមានឡើងថ្មីៗនៅលើពិភពលោក និងចូលរួមសិក្សាស្រាវជ្រាវបន្ថែមពីមូលហេតុដែលបណ្តាលឱ្យប្រទេសមួយចំនួនកើតមានបន្ទុះភ្នំភ្លើងបានជាប្រចាំ។

**២. ចំណេះដឹងមូលដ្ឋាន៖**

បន្ទុះភ្នំភ្លើងគឺជាបាតុភូតដែលគួរឱ្យភ័យខ្លាចនៅលើភពផែនដី ។ ភ្នំភ្លើងគឺជាភ្នំដែលកើតឡើងនៅពេលសិលារលាយហៅថា ម៉ាក់ម៉ាហូរចេញមកលើភពផែនដី ។ ម៉ាក់ម៉ាគឺជាសិលារាវដែលផ្សំពីសិលារលាយ ឧស្ម័ន ទឹកមានប្រភពនៅក្នុងម៉ង់តូ ។ នៅពេលម៉ាក់ម៉ាឡើងមកដល់ផ្ទៃលើភពផែនដីគេហៅថាកំអែភ្នំភ្លើង ។ នៅពេលកំអែភ្នំភ្លើងចុះត្រជាក់ និងកករឹងវាក្លាយជាសិលាភ្នំភ្លើង ។

នៅលើទ្វីបមានភ្នំភ្លើងសកម្មប្រហែល ៦០០ កើតឡើង ហើយភ្នំភ្លើងខ្លះទៀតកើតឡើងនៅក្នុងសមុទ្រធ្វើឱ្យអ្នកវិទ្យាសាស្ត្រពិបាកក្នុងការសង្កេត និងធ្វើផែនទីណាស់។ ភ្នំភ្លើងភាគច្រើនផ្ទុះនៅតាមព្រំដែនបែកចេញដូចជានៅតាមទ្រនុងកណ្តាលមហាសមុទ្រ តាមព្រំដែនជំនួបគ្នា និងនៅកណ្តាលទ្វីបផងដែរ គឺ ភ្នំភ្លើងនៅចំណុចក្តៅ។

ភ្នំភ្លើងអាចមានកម្លាំងខ្លាំងជាងគ្រាប់បែកអាតូមិចដែលគេប្រើក្នុងសង្គ្រាមលោកលើកទី២ដល់ទៅជាង ១០០០០ ដង ហើយបន្ទុះភ្នំភ្លើងនោះមានពីរបែបគឺ បន្ទុះខ្លាំង និងបន្ទុះស្ងប់ ។ បន្ទុះស្ងប់ ផ្សំពីទឹកច្រើន និងស៊ីលីកាតិចធ្វើឱ្យកំហាប់រាវមានលំហូរជាប្រចាំ និងមានឧស្ម័នភាយចេញពីម៉ាក់ម៉ា ហើយបង្កើតមាន ទន្លេកំអែភ្នំភ្លើងក្តៅពណ៌ក្រហមដែលហូរចេញមកពីបន្ទុះភ្នំភ្លើងស្ងប់ហៅថា លំហូរកំអែភ្នំភ្លើង។ កំអែភ្នំភ្លើង គឺជាម៉ាក់ម៉ាដែលហូរឡើងមកដល់ផ្ទៃលើផែនដី ហើយហូរចេញមកក្រៅដោយស្ងប់ស្ងាត់អាចបញ្ចេញនូវបរិមាណសិលារលាយដ៏ច្រើន ដែលបង្កើតឱ្យមានកំអែភ្នំភ្លើងជាច្រើនប្រភេទ(កំអែភ្នំភ្លើងខាប់ ក្រមួន គ្រើម និងរាងខ្នើយ)។

នៅក្នុងបន្ទុះខ្លាំង មានពំនូកនៃកម្ទេច និងឧស្ម័នក្តៅបានព្រួសចេញពីភ្នំភ្លើងក្នុងល្បឿនលឿនជាងសំឡេង ។ បន្ទុះនេះធ្វើឱ្យសិលារលាយបាចសាចជាបំណែកតូចៗរាប់លានកករឹងក្នុងបរិយាកាស ដោយសារ ម៉ាក់ម៉ាមានកំហាប់ខ្ពស់(ស៊ីលីកាច្រើន) រឹង និងងាយកកស្ទះមាត់បំពង់បង្កើតជាសំពាធខ្លាំងមួយ។ ក្រៅពីបញ្ចេញសិលារលាយចូលក្នុងអាកាស បន្ទុះខ្លាំងក៏អាចផ្ទុះបំបែកសិលារាប់លានតោនពីភ្នំភ្លើងផងដែរ ។ដែលបង្កើតឱ្យមានបំណែកសិលាដូចជា ដុំសិលាភ្នំភ្លើង គ្រាប់បែកភ្នំភ្លើង ផេះភ្នំភ្លើង និងធូលីភ្នំភ្លើង ។

**៣. ណែនាំដំណើរការពិសោធន៍**

- ការប្រើប្រាស់សម្ភារៈពិសោធន៍
  - ណែនាំដល់សិស្សចំពោះការកាន់ និងប្រើប្រាស់កែវ បេស៊ែ ដែលអាចងាយរលំឬបែក ឬធ្លាក់បែកជាដើម នៅកំឡុងពេលធ្វើពិសោធន៍។
  - ណែនាំដល់សិស្សចំពោះការកាន់ និងប្រើប្រាស់ទឹកខ្មេះ បើអាចពាក់ស្រោមដៃការពារពេលចាក់ទឹកខ្មេះ។
  - ណែនាំដល់សិស្សចំពោះការប្រើប្រាស់ឈើគូសចៀសវាងមានអគ្គីភ័យកើតឡើង។

# សន្លឹកកិច្ចការសិស្ស

## សកម្មភាពទី១. ការបង្កើតសំណួរគន្លឹះ

| ចូរបកស្រាយពីបន្ទុះខ្លាំង និងបន្ទុះស្ងប់នៃភ្នំភ្លើង។ |
|---|

## សកម្មភាពទី២. ការបង្កើតសម្មតិកម្មសំណួរគន្លឹះខាងលើ

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

## សកម្មភាពទី៣. ធ្វើតេស្តសម្មតិកម្ម /ពិសោធន៍

- សម្ភារពិសោធន៍៖ (ចូរប្អូនរៀបរាប់ពីសម្ភារៈពិសោធន៍)

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

- ដំណើរការពិសោធន៍៖ (ចូរប្អូនរៀបរាប់ពីដំណើរការពិសោធន៍)

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

## ៤.លទ្ធផល៖ (សរសេរនូវអ្វីដែលប្អូនបានឃើញ)

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

## ៥. វិភាគ និងសន្និដ្ឋាន៖ (បរិយាយពីបន្ទុះខ្លាំង និងបន្ទុះស្ងប់)

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................